អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីអញ្ជើញចូលរួមក្នុងសវនាការរបស់អង្គបុរេជំនុំជម្រះនៃអ.វ.ត.ក

ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០០៨

អង្គបុរេជំនុំជម្រះ នៃអ.វ.ត.កបានកំណត់ថ្ងៃបើកសវនាការសាធារណៈនាថ្ងៃទី ២០ ខែមីនា ឆ្នាំ២០០៨ ដែលនិងចេញសេចក្តីសម្រេចទៅលើ ១) ករណីការចូលរួមនៃដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន ២) ករណីបណ្តឹងឧទ្ធរណ៍របស់ នួន ជាប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន។

អង្គបុរេជំនុំជម្រះបានសំរេច និងអនុញ្ញាតិឲ្យមានការផ្សាយបន្តផ្ទាល់ពីដំណើរការសវនាការទៅដល់ស្ថានីយវិទ្យុ និងទូរទស្សន៍សំរាប់ផ្សព្វផ្សាយជាសាធារណៈ។ តំណាងប្រព័ន្ធសារព័ត៌មាននីមួយៗនិងសាធារណៈជនទូទៅនឹងត្រូវបានអញ្ជើញចូលរួមដោយផ្ទាល់នៅក្នុងសវនាការនោះ ។ ឧកាសសំរាប់ថតរូបនិងត្រូវផ្តល់តាមដែលចំនួនត្រូវបានកំណត់នៅគ្រាដែលសវនាការចាប់ផ្តើម។

សវនាការនឹងចាប់ផ្តើមនាវេលាម៉ោង ១០:០០: ព្រឹក នៅថ្ងៃទី ២០ ខែមីនា ។ អ្នកចូលរួមទាំងអស់ត្រូវមានវត្តមាននៅកន្លែងអង្គុយដែលបំរុងទុករយៈពេល ៣០ នាទីមុនពេលសវនាការចាប់ផ្តើម។ អ្នកចូលរួមទាំងអស់តំរូវឲ្យមកដល់បរិវេណអ.វ.ត.កក្នុងចន្លោះពីម៉ោង ០៨:០០ ដល់ម៉ោង០៨:៣០ព្រឹកដើម្បីទុកពេលឲ្យសន្តិសុខធ្វើការត្រួតពិនិត្យនិងចេញប័ណ្ណ។ ក្លោងទ្វាមុខនឹងបិទនៅវេលាម៉ោង០៩:៣០ព្រឹក ឬនៅពេលដែលកន្លែងអង្គុយនៅក្នុងសាលសវនាការពេញអស់។

អ្នកចូលរួមទាំងអស់ត្រូវបង្ហាញអត្តសញ្ញាណសំគាល់ដែលមានភ្ជាប់រូបថត ហើយត្រូវឆ្លងកាត់ការត្រួតពិនិត្យផែកឆេររបស់សន្តិសុខ។ សូមកត់សំគាល់ផងដែរថាបុគ្គលក្រោមអាយុ១៨ឆ្នាំនឹងមិនអនុញ្ញាតិឲ្យចូលក្នុងសាលសវនាការនោះទេ។ ទូរស័ព្ទ កាបូបធំៗ ចំណីអាហារនិង ភេសជ្ជៈនឹងត្រូវហាមឃាត់មិនអោយនាំចូលក្នុងសាលសវនាការនោះទេ។

**កន្លែងអង្គុយនៅក្នុងសាលសវនាការបានរៀបចំដូចខាងក្រោមនេះ ៖**

**អ្នកសារព័ត៌មាន៖** ត្រូវតម្រូវអោយចុះឈ្មោះមុន។ កាលបរិច្ឆេទ ថ្ងៃព្រហស្បត៍ ទី១៩ ខែមីនា វេលាម៉ោង ១២:០០ ថ្ងៃត្រង់ ។ ក្នុងករណីចំនួននៃកន្លែងអង្គុយនេះនៅទំនេរមុនម៉ោង ១០:០០ព្រឹក នៅថ្ងៃសវនាការ កន្លែងទាំង

នោះនឹងរៀបចំសំរាប់សាធារណៈជនទូទៅ។ សំរាប់ព័ត៏មានបន្ថែមនិងការសំរបសំរួលផ្សេងៗសូមមើលក្នុងសេចក្តីប្រកាសព័ត៏មានសំរាប់ប្រព័ន្ធផ្សព្វផ្សាយឬទាក់ទងលោកម៉ៅ វុត្ថាតាមរយៈទូរស័ព្ទលេខ ០២៣ ២១៩ ៨១៤ និងចុចលេខបន្ត ៦១៦៦, ឬ ០១១ ៣៦៤ ៤៤៤ ឬក៏បញ្ជូនតាមអ៊ីម៉េល mao.vutha@eccc.gov.kh។

**អង្គការក្រៅរដ្ឋាភិបាល៖** កន្លែងអង្គុយចំនួន ៥០បានបំរុងទុក សំរាប់ទាំងអង្គការជាតិនិងអន្តរជាតិ(អង្គការនីមួយៗអាចមានសិទ្ធិទទួលកន្លែងអង្គុយចំនួន២ ) និងទាមទារឲ្យមានការចុះឈ្មោះជាមុន។ កាលបរិច្ឆេទផុតកំនត់សំរាប់ការចុះឈ្មោះគឺនាថ្ងៃព្រហស្បត៍ ទី១៩ ខែមីនា វេលាម៉ោង ១២:០០ ថ្ងៃត្រង់ ។ ក្នុងករណីកន្លែងអង្គុយទាំងនោះនៅសល់មុនម៉ោង ១០ព្រឹក នៅថ្ងៃសវនាការ កន្លែងអង្គុយទាំងនោះនឹងអោយរៀបចំជូនសំរាប់សាធារណៈជនទូទៅ។

**ក្រុមផ្សេងៗ៖** កន្លែងអង្គុយចំនួន ១៤០បំរុងទុកសំរាប់ក្រុមផ្សេងៗ (កន្លែងអង្គុយចំនួន ២០ សំរាប់ក្រុមនិមួយៗ)។ កាលបរិច្ឆេទផុតកំនត់សំរាប់ការចុះឈ្មោះគឺនាថ្ងៃព្រហស្បត៍ ទី១៩ ខែមីនា វេលាម៉ោង ១២:០០ ថ្ងៃត្រង់ ក្នុងករណីកន្លែងអង្គុយសំរាប់ក្រុមផ្សេងៗនៅទំនេរមុនម៉ោង  ១០ព្រឹក នៅថ្ងៃសវនាការ កន្លែងអង្គុយទាំងនោះនឹងអោយរៀបចំជូនសំរាប់សាធារណៈជនទូទៅ។

**សាធារណៈជនទូទៅ៖**

សាធារណៈជនទូទៅត្រូវបានលើកទឹកចិត្តក្នុងការចុះឈ្មោះជាមុនហើយអ្នកដែលមកមុននឹងទទួលបានកន្លែងអង្គុយមុន។ កន្លែងអង្គុយសំរាប់សាធារណៈជនមានបំរុងទុកចំនួន ១០០ កន្លែង។ ក្នុងករណីលោកអ្នកត្រូវការធ្វើដំណើរតាមរថយន្តក្រុងរបស់អ.វ.ត.ក ដោយឥតគិតថ្លៃ គឺលោកអ្នកត្រូវធ្វើការចុះឈ្មោះជាមុន។

**មធ្យោបាយធ្វើដំណើរ** ៖ អ.វ.ត.ក នឹងផ្តល់សេវាកម្មធ្វើដំណើរដោយឥតគិតថ្លៃសំរាប់អ្នកសារព័ត៏មាន ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណៈជនដែលមិនមានមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនទាំងទៅនិងមកកាន់ អ.វ.ត.ក។ រថយន្តក្រុងនឹងចាកចេញពីមុខស្ពានីយរាជាយស្ម័យានពីចន្លោះម៉ោង ០៧:៣០ ដល់ម៉ោង០៨:០០ នៅរាល់ថ្ងៃសវនាការ។ សំរាប់អ្នកត្រូវការសេវាកម្មនេះគឺទាមទារឲ្យមានការចុះឈ្មោះជាមុន។

អ.វ.ត.ក មានទីតាំងស្ថិតនៅសង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ៤ចំងាយប្រមាណ១៦គីឡូម៉ែត្រពីវត្តភ្នំ។សាធារណៈជននិងតំណាងសារព័ត៏មាននានាសូមអញ្ជើញចូលតាមច្រកទ្វាសំរាប់

អ្នកចូលទស្សនាដែលស្ថិតនៅប៉ែកខាងកើតនៃបរិវេណអ.វ.ត.ក។

**ការសំរបសំរួលទូទៅ** ៖ ទឹកបរិសុទ្ធមានដាក់នៅផ្លូវចូលនៅខាងក្រៅសាលសវនាការ។ ភេសជ្ជៈនិងអាហារហាមនាំចូលក្នុងសាលសវនាការ។ បង្គន់អនាម័យមាននៅក្នុងអាគារសវនាការនិងចំណតរថយន្ត។ ចំណតរថយន្តមានបំរុងទុកសំរាប់អ្នកចូលរួមដែលប្រើមធ្យោបាយផ្ទាល់ខ្លួនរាប់ទាំងរថយន្តក្រុងនិង រថយន្តតូច។ ជាជំនួយសំរាប់ជនពិការក៏មានផ្តល់ជូនផងដែរដូចជាទេះរុញ។

ការចុះឈ្មោះសំរាប់សាធារណៈជនទូទៅនិងសេវាកម្មធ្វើដំណើរសូមទាក់ទងមកកាន់
លោកជឹន ហេមវិចិត្រ
ទូរសព្ទ័: (០២៣)២១៩៨១៤ លេខបន្ត:៦០៦៥
ទូរសព្ទ័ដៃ: (០១២) ៦៩៦ ២២០
ទូរសារ: (855) 023 ២១៩៨១៤ លេខបន្ត:៦០៦៩
អ៊ីម៉េល: info@eccc.gov.kh